ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៦ សរណន

# សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបលើកទី៣២ ទិវាជនពិការអន្តរជាតិ ៣ធ្នូ និងខួបលើកទី១៦ ទិវាជនពិការកម្ពុជា ឆ្នាំ២០១៤

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ៣ធ្នូ ដើម្បីរំលឹកដល់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើវិស័យពិការភាព ជាពិសេសបងប្អូនជនពិការកម្ពុជា ស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការ និងបទដ្ឋានជាតិ អន្តរជាតិស្តីពីសិទ្ធិជនពិការ។

ទិវាជនពិការអន្តរជាតិត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកអំពីការតស៊ូទាមទារសិទ្ធិចូលរួមក្នុងសង្គមរបស់ជនពិការប្រមាណជាង ៥លាននាក់នៅក្នុងពិភពលោក ដែលជាជនបាត់បង់កាយសម្បទា កាយវិញ្ញាណ និងសតិបញ្ញា និងតែងតែជួបប្រទះនូវឧបសគ្គរាំងក្នុងជីវិត ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ នៅសហរដ្ឋអាមេរិក និងអឺរុប សំដៅធ្វើការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគេ ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព ដោយផ្តោតសំខាន់លើសិទ្ធិជនពិការ និងការធ្វើសមាហរណកម្មជនពិការទៅក្នុងគ្រប់សកម្មភាព នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាជនពិការនេះឡើង គឺដើម្បីរំលឹកអំពីមហាវិនាសកម្មក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ក្នុងនោះរួមមានស្ត្រីមេម៉ាយ កុមារកំព្រា និងជនពិការ ព្រមទាំងគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពរងគ្រោះមួយចំនួនទៀតដែលនាំឱ្យពិការ ដូចជាគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងៗទៀត។

ដោយមានការយកចិត្តទុកដាក់ខ្ពស់ចំពោះជនពិការនៅកម្ពុជា រាជរដ្ឋាភិបាល កាលពីថ្មីៗកន្លងទៅនេះ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដែលជាសមិទ្ធផលថ្មីមួយទៀតក្នុងវិស័យពិការភាព បន្ទាប់ពីការអនុវត្តផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ដែលបានបញ្ចប់ដោយជោគជ័យ កាលពីចុងឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រនេះគឺជាមូលដ្ឋានគ្រឹះនិងជាឆ្អឹងខ្នងដ៏សំខាន់មួយទៀតដែលមិនអាចខ្វះបាន សម្រាប់ការអនុវត្តតួនាទីលើកកម្ពស់ជីវភាព និងសិទ្ធិជនពិការនៅកម្ពុជា ដែលកិច្ចការនេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការបន្តជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក សម្រាប់ឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ «ធ្វើឱ្យសិទ្ធិក្លាយជាការពិត» និងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានផ្តល់កម្មសិទ្ធិដីធ្លីនិងបានកសាងលំនៅឋានជូនជនពិការតាកែនកោះស្លា តំបន់អភិវឌ្ឍន៍ជនពិការ៣១៧ នៅស្រុកគូលែន ខេត្តសៀមរាប និងនៅភ្នំធំត្រ ខេត្តបន្ទាយមានជ័យ។ យើងក៏បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ ដើម្បីចូលរួមចំណែកជួយដល់ជនពិការក្រីក្រ លើកកម្ពស់ជីវភាព ការអប់រំ

ការព្យាបាល ការស្តារលទ្ធភាពពលកម្ម កាយសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈនិងមុខរបរ ជាពិសេសសម្រាប់ជនពិការគថ្លង់ និងជនពិការភ្នែកផងដែរ។ ជាក់ស្តែង យើងបានរៀបចំបង្កើតឱ្យមានអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនពិការភ្នែក និងជនពិការគថ្លង់ និងបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៃវិស័យអប់រំ បញ្ចូលទៅក្នុងព័ត៌មានវិទ្យា និងតាមស្ថានីយទូរទស្សន៍នានា ដើម្បីផ្តល់ឱកាសឱ្យជនពិការអាចទទួលបាននូវព័ត៌មានយ៉ាងទូលំទូលាយ។ ជាមួយគ្នានេះ កុមារពិការក៏បានទទួលឱកាសសម្រាប់ការសិក្សាអប់រំនៅតាមសាលារៀនសាធារណៈ ដោយមិនមានការរើសអើង។ អគារសិក្សាមួយចំនួនបានរៀបចំឱ្យមានជម្រាលសម្រាប់សិស្សពិការ ហើយមជ្ឈមណ្ឌលនិងសាលារៀនសម្រាប់កុមារពិការភ្នែកនិងគថ្លង់ ក៏ទទួលបាននូវតម្រូវការខាងជីវភាពរស់នៅដើម្បីផ្តល់ជូនដល់កុមារពិការភ្នែកនិងគថ្លង់ និងផ្តល់ឱកាសសិក្សាអប់រំរហូតដល់កម្រិតឧត្តមសិក្សា។ បច្ចុប្បន្ននេះ មានជនពិការមួយចំនួនបានក្លាយជាបុគ្គលិកប្រកបដោយសមត្ថភាពផងដែរ។

ដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៦ និងទិវាជនពិការអន្តរជាតិលើកទី៣២ ឆ្នាំ២០១៤នេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងដូចតទៅ៖

១. ទិវាជនពិការកម្ពុជាលើកទី១៦ និងទិវាជនពិការអន្តរជាតិលើកទី៣២ ត្រូវប្រារព្ធក្រោមប្រធានបទ **«ផ្តល់លទ្ធភាពអាចប្រើប្រាស់បាន រួមបញ្ចូលទាំងមុខរបរ ការងារ និងបច្ចេកវិទ្យា ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព»**។

២. ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូល ដើម្បីបានជ្រួតជ្រាបអំពីប្រវត្តិនៃទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ៣ធ្នូ។

៣. គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយជនពិការ កម្មវិធីកម្សាន្តសប្បាយរបស់ជនពិការនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ-ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៤. ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិជនពិការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់ជនពិការនៅរាជធានីភ្នំពេញ។

៥. គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ-ឯកជន ត្រូវរៀបចំចងបដាពាក្យស្លោក ដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៦ និងទិវាជនពិការអន្តរជាតិលើកទី៣២ ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- រួមគ្នាដាក់បញ្ចូលពិការភាពក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
- ចូលរួមកាត់បន្ថយហានិភ័យ និងឆ្លើយតបគ្រោះមហន្តរាយឱ្យទាន់ពេលវេលា
- លើកកម្ពស់ការផ្តល់បរិស្ថានការងារសមស្របសម្រាប់ជនពិការ
- កាត់បន្ថយភាពក្រីក្ររបស់ជនពិការដើម្បីបង្កើនជីវភាពសមរម្យ
- ពង្រឹងភាពជាម្ចាស់ការរបស់ជនពិការ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ